ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់ស្តីពី

# សុខភាពសត្វ និងផលិតកម្មសត្វ

# Law on
# Animal Health and Production

ខែកុម្ភៈ ឆ្នាំ២០១៦

នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបត្ថម្ភបោះពុម្ពដោយៈ សហភាពអឺរ៉ុប

តាមរយៈៈ កម្មវិធី EU-PGA-L

# ព្រះរាជក្រម

នស/រកម/០១១៦/ ០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# សុខភាពសត្វ
# និងផលិតកម្មសត្វ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងដូចតទៅ ៖

- ធានាការគ្រប់គ្រង និងការអភិវឌ្ឍសុខភាពសត្វ និងផលិតកម្មសត្វ
- ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ និងការពារបរិស្ថាន
- បង្ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ
- ការពារធនធានសត្វ និងពូជសត្វរបស់ជាតិ
- ធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងសុខភាពសត្វ និងផលិតកម្មសត្វ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ព្រះរាជាណាចក្រកម្ពុជាកំណត់ថ្ងៃទី ៤ ខែ តុលា រៀងរាល់ឆ្នាំ ជាសត្តទិវាជាតិរួមជាមួយនឹងសត្តទិវាអន្តរជាតិ ។

**មាត្រា ៥.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
# សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៦.-**

ការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។